# ក្រុម ២៣ តុលា ១៩៩១
**GROUPE 23 OCTOBRE 1991**

« ចេះឯងឲ្យក្រែងចេះគេ កុំអង្គុយលើចង្កេរលើកខ្លួនឯង »

Correspondance : 25, Avenue de la Liberté, 93420 Villepinte (France)

Président: PEN Vano Tél. : (+33) 7 82 03 41 56

E.Mail : *penvano@hotmail.com*

LA VOIX DES KHMERS NATIONALISTES


---

# សេចក្តីថ្លែងការណ៍
## នៅក្នុងឱកាសខួបទី ៤៤ ឆ្នាំប្រឆាំងយួនឈ្លានពានកម្ពុជា
## ថ្ងៃទី០៧ មករា ឆ្នាំ២០២៣

---

## ៧ មករា ១៩៧៩ ជាថ្ងៃយួនឈ្លានពានទឹកដីខ្មែរ !!! បើគ្មានថ្ងៃ២៣តុលា ១៩៩១ ផែនការ <ក៥>នឹងបំផុតពូជខ្មែរបាត់អស់ទៅហើយ !!!

**បងប្អូនរួមជាតិជាទីគោរពស្នេហា !**

ថ្ងៃនេះ គឺជាថ្ងៃទី ០៧ មករា ឆ្នាំ ២០២៣ គឺជាខួបទី ៤៤ ឆ្នាំ នៃការដែលយួនបានឈ្លានពានកម្ពុជា។ សេចក្តីថ្លែងការណ៍នេះ « **ក្រុម ២៣ តុលា ១៩៩១** /**បារាំង** » មានគោលបំណងដើម្បីសំដែងការប្រឆាំងរបស់យើងចំពោះពាក្យឃោសនារបស់ពួកអាយ៉ងយួននៅក្រុងភ្នំពេញដែលតែងបានអួតសរសើរថា ថ្ងៃ៧មករា១៩៧៩ គឺជាថ្ងៃដែលខ្មែរត្រូវអរគុណាយួនដែលបានចូលមកជួយរំដោះជាតិខ្មែរយើងពីរបបប្រល័យពូជសាសន៍ ប៉ុល ពត។ ការពិត បើគ្មានថ្ងៃ២៣ តុលា ១៩៩១ ទេនោះ ប្រហែលជាផែនការ <**ក៥**> បានបំផុតពូជខ្មែរបាត់អស់ទៅហើយ។

៧ មករា ១៩៧៩ គឺជាល្បិចយួនក្នុងមហិច្ឆិតាដ៏ខ្មៅក្រខ្វក់របស់វាគឺសម្លាប់ខ្មែរឲ្យផុតពូជដើម្បីលេបត្របាក់តែទឹកដីខ្មែរតែប៉ុណ្ណោះ។ ដោយពួកវាបានយកខ្មែរមួយក្រុមមកបញ្ហារបង្កើតជាក្រុមអាចោរមកកាប់សម្លាប់ខ្មែរអស់ជិត២លាននាក់ បន្ទាប់មកពួកវាបានយកខ្មែរមួយក្រុមទៀតបង្កើតជាក្រុមអាគិញមកបញ្ជារ និងបណ្តេញពួកអាចោរ ដោយបានប្រើដៃខ្មែរឲ្យសម្លាប់ខ្មែរដោយឥតញញើតដៃរហូតមកដល់សព្វថ្ងៃនេះ បានដោយប្រសិទ្ធភាពជាទីបំផុត សមដូចពាក្យខ្មែរតែងពោលថា: < អូសទូកកុំឲ្យល្អាន ចាប់ត្រីបានកុំឲ្យល្អក់ទឹក > យ៉ាងដូច្នោះដែរ។ ឥឡូវយួនលេបខ្មែរជិតអស់មែនទែនហើយ ហើយយួននៅតែគ្រហើៗ ហើយក៏នៅមានខ្មែរខ្លះនៅតែគាំទ្រ៧មករា ១៩៧៩យ៉ាងផ្កាប់មុខតទៅទៀរផង...។

បើសិនជាគ្មាន២៣តុលាមកជួយទប់ ម្ល៉េះផែនការ <**ក៥**> របស់៧មករា ១៩៧៩នៅតែបន្តបំផុតពូជខ្មែរ តទៅទៀតជាមិនខានឡើយ។ ហេតុយ៉ាងដូច្នេះហើយ បានជាពួកអាគិញចេញពី៧មករា ១៩៧៩ វាប្រឆាំងនឹងថ្ងៃ ២៣តុលា ១៩៩១ ខ្លាំងណាស់ ពីព្រោះ២៣តុលាជាឧបសគ្គ:រារាំងល្បិចកល្ប៍

ពួកយួន មិនឲ្យលេបត្របាក់ទឹកដីខ្មែរបាន។ ពួកវាបានបានលុបថ្ងៃជាប្រវត្តិសាស្ត្រនេះចោលចេញពីបញ្ជីរថ្ងៃបុណ្យជាតិ រួចហើយពួកវាបានរក្សាថ្ងៃ៧មករាជាថ្ងៃបុណ្យជាតិរហូតមកដល់សព្វថ្ងៃនេះ ។

ជាក់ស្តែងណាស់ ការឈ្លានពានទឹកដីខ្មែរនៅតែបន្តឥតឈប់រហូតមកដល់សព្វថ្ងៃនេះ ដូចជាការបោះបង្គោលព្រំដែនថ្មីជាដើម។ ២៣តុលា ១៩៩១ បានតម្រូវឲ្យកងទ័ពបរទេសដកចេញឲ្យអស់ពីទឹកដីខ្មែរ ម្តេចឡើយក៏មានមូលដ្ឋានយោធាចិននៅរាមនៃប្រទេសកម្ពុជាបានយ៉ាងដូច្នេះ?។

យើងខ្ញុំ« **ក្រុម ២៣ តុលា ១៩៩១ /បារាំង** » ជាក្រុម**ខ្មែរ**ស្នេហាជាតិ សូមប្រកាសថ្កោលទោសយ៉ាង ដាច់អហង្ការចំពោះល្បិចកល្ប៍ដ៏ ខ្មៅក្រខ្វក់របស់យួនឈ្លានពានទឹកដីខ្មែរនេះនិងសូមធ្វើសេចក្តីអំពាវ នាវជាឧឡារិកដូចតទៅនេះ :

១/- ចំពោះតុលាការឧក្រិដ្ឋកម្មអន្តរជាតិ (I.C.C) នៅទីក្រុងឡាអេ មេត្តាលើកយកករណីយួនឈ្លានពានប្រទេសកម្ពុជាដ៏ជាក់ស្តែងនេះមកវិនិច្ឆ័យនិងធ្វើការផ្តន្ទាទោសជាគំរូក្នុងពេលដ៏ឆាប់ៗនេះដោយ សេចក្តីអនុគ្រោះ។

២/- ចំពោះអង្គការសហប្រជាជាតិ ចពោះក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ ចំពោះសហភាពអឺរ៉ុប និងចំពោះប្រទេសបារាំងនិងប្រទេសឥណ្ឌូនេស៊ីដែលជាសហប្រធាននៃសន្និសិទអន្តរជាតិនៅក្រុង ប៉ារីស៍ ស្តីពីប្រទេសកម្ពុជាថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ មេត្តាជួយជំរុញឲ្យមានការកោះប្រជុំសន្និសិទអន្តរជាតិនេះជាថ្មីម្តងទៀត និងជាបន្ទាន់បំផុតដើម្បីស្វែងរកដំណោះស្រាយជាស្ថាពរចំពោះសោកនាដ្យកម្មដ៏រ៉ាំរ៉ៃ នៃប្រជារាស្ត្រខ្មែដ៏អភ័ព្វនេះ និងដើម្បីធ្វើការផ្តន្ទាទោសជាគំរូចំពោះប្រទេសដែលជាហត្ថលេខីទាំងឡា ណាដែលបានរំលោភកិច្ចព្រមព្រៀងជាអន្តរជាតិនេះផង។

ឆ្លៀតក្នុងឱកាសនេះ យើងខ្ញុំ « **ក្រុម ២៣ តុលា ១៩៩១ /បារាំង** » ជាក្រុម **ខ្មែរ** ស្នេហាជាតិទាំងអស់ សូមធ្វើសេចក្តីអំពាវនាវចំពោះបងប្អូនគ្រប់និន្នាការនយោបាយទាំងអស់មេត្តាយល់ថារឿងវិបត្តិនយោបាយខ្មែរដ៏ធ្ងន់ធ្ងរដូចសព្វថ្ងៃនេះ ទាមទារឲ្យមានដំណោះស្រាយតាមផ្លូវអន្តរជាតិជាបន្ទាន់ហើយ។ ដើម្បីឲ្យសហាគមន៍អន្តរជាតិគេអាចជួយយើងបាន មហាសាមគ្គីជាតិខ្មែរគឺជាលក្ខណ្ឌដ៏ចំបងបំផុត។

ធ្វើនៅទីក្រុងប៉ារីស៍ ថ្ងៃទី ០៧ ខែមករា ឆ្នាំ២០២៣

**ប្រធាន « ក្រុម ២៣ តុលា ១៩៩១ /បារាំង »**



**ប៉ែន វ៉ាណូ**